

ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែធ្នូ ឆ្នាំ២០១៧ លេខ ១១

## វឌ្ឍនភាពប្រចាំឆ្នាំ
## គម្រោងការបញ្រ្ជាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ – កញ្ចប់ “Package A”

គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ការបញ្រ្ជាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ --កញ្ចប់ “Package A” សម្រេចបានលទ្ធផលសំខាន់ៗមួយចំនួន ក្នុងឆ្នាំ២០១៧ ដើម្បីជួយពង្រឹងសមត្ថភាពក្រសួងស្ថាប័នពាក់ព័ន្ធលើការរៀបចំផែនការអភិវឌ្ឍន៍ភាពធន់នឹងអាកាសធាតុ ដោយគិតគូរពីយេនឌ័រផងដែរ។

ចំណុចសំខាន់ៗមួយចំនួនដែលសម្រេចបាន រួមមាន៖

**លទ្ធផលទី១៖ ការសម្របសម្រួល និងការកសាងសមត្ថភាពលើភាពធន់នឹងអាកាសធាតុ (ការសម្របសម្រួលកម្មវិធីSPCR ការគាំទ្របច្ចេកទេស និងសមត្ថភាពដើម្បីបញ្រ្ជាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ត្រូវបានពង្រឹង)**







***ឯកសារចងក្រងការអនុវត្តភាពធន់នឹងអាកាសធាតុ***

- មគ្គុទេសក៍បន្សាំ ត្រូវបានរៀបចំរួចនិងផ្ញើជូនក្រសួងពាក់ព័ន្ធ រួមទាំងធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីអនុម័តលើ៖ មគ្គុទេសក៍ស្តីពីបន្សាំវិស័យកសិកម្ម មគ្គុទេសក៍ស្តីពីបន្សាំវិស័យធនធានទឹក មគ្គុទេសក៍ស្តីពីហេដ្ឋារចនាសម្ព័ន្ធបៃតង មគ្គុទេសក៍ស្តីពីហេដ្ឋារចនាសម្ព័ន្ធជនបទបៃតង។







## មាតិកា

វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគផ្លូវលំជនបទ.................ទំព័រ ៤
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ.................ទំព័រ ៤
កិច្ចប្រជុំលើកទី៧របស់ក្រុមការងារសម្របសម្រួលកម្មវិធី...........ទំព័រ ៧
ការប្រែប្រួលអាកាសធាតុ និងសហគមន៍ជនជាតិដើមភាគតិច....ទំព័រ ៨
វឌ្ឍនភាពស្តីពីយេនឌ័រក្នុងការឆ្លើយតបនឹងការប្រែប្រួល............ទំព័រ ៩
សមិទ្ធផលសំខាន់ៗក្នុងការបញ្រ្ជាបភាពធន់នឹងអាកាសធាតុ..ទំព័រ ១០
កម្ពុជាពីប្រទេសមិនសូវស្គាល់បរិស្ថាន បានក្លាយជាអ្នកចែក...ទំព័រ ១១
គណៈប្រតិភូជាតិ និងអន្តរជាតិជាង ១០០ នាក់.....................ទំព័រ ១២
សកម្មភាពបន្ទាប់........................................................ទំព័រ ១៤

- ឯកសារការអនុវត្តបែបប្រពៃណី និងជនជាតិដើមភាគតិចសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា ត្រូវបានចងក្រងរួច និងផ្ញើជូនក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីអនុម័ត។
- កិច្ចពិភាក្សាតុមូលស្តីពីវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍក្រុង បានរៀបចំកាលពីខែមីនា និងមេសា ដើម្បីប្រមូលធាតុចូលបន្ថែមទៀតពីក្រសួងពាក់ព័ន្ធក្នុងការធ្វើឱ្យមគ្គុទេសក៍ទាំងនេះកាន់តែល្អប្រសើរឡើង។
- ឧបករណ៍កំណត់ហានិភ័យការប្រែប្រួលអាកាសធាតុ ការព្យាករអាកាសធាតុ និងប្រព័ន្ធទិន្នន័យអាកាសធាតុ ត្រូវបានរៀបចំឱ្យស្របនឹងបរិបទប្រទេសកម្ពុជា និងកំពុងត្រូវបានបន្ថែមបន្ថយធាតុចូលសម្រាប់វិស័យនីមួយៗ។
- ការផ្តួចផ្តើមពិគ្រោះយោបល់ស្តីពីគោលការណ៍បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ត្រូវបានពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ អំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារសម្របសម្រួលកម្មវិធី SPCR លើកទី៦ក្នុងខែកក្កដា និងលើកទី៧ ក្នុងខែធ្នូ ឆ្នាំ២០១៧ រួមទាំងការកំណត់នូវបទដ្ឋានបច្ចេកទេស ឧបករណ៍ និងដំណើរការដែលត្រូវបង្កើតសម្រាប់វិស័យនីមួយៗ។
- កិច្ចប្រជុំតុមូលលើការវាយតម្លៃតម្រូវការកសាងសមត្ថភាពពាក់កណ្តាលអាណត្តិ នៃការអនុវត្តគម្រោងវិនិយោគរបស់កម្មវិធី SPCR និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំឡើងនៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៧ ដើម្បីប្រៀបធៀបទិន្នន័យដើមគ្រាដែលបានប្រមូលកាលពីឆ្នាំ ២០១៥ នៅដំណាក់កាលនៃការចាប់ផ្តើមអនុវត្តគម្រោង។

### *សូចនាករសម្រាប់ការត្រួតពិនិត្យប្រសិទ្ធភាពនៃការបន្សាំ*

- ការពិគ្រោះយោបល់លើសូចនាករសម្រាប់ការត្រួតពិនិត្យប្រសិទ្ធភាពនៃការបន្សាំ ត្រូវបានពិភាក្សាអំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារសម្របសម្រួលកម្មវិធី SPCR កាលពីនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ និងបានរៀបចំជារបាយការណ៍៖ សូចនាករនៃការបន្សាំដែលមានប្រសិទ្ធភាព។

### *ការបង្កើនឧបករណ៍ដើម្បីរៀបចំផែនការភាពធន់អាកាសធាតុ*

- បន្ទាប់ពីបានរៀបចំការបណ្តុះបណ្តាលជាលើកដំបូងនៅក្នុងឆ្នាំ២០១៦ ការបណ្តុះបណ្តាលលើកទី២ស្តីពីការធ្វើតេស្តសាកល្បងប្រើប្រាស់ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបចំកាលពីថ្ងៃទី៤ ខែកញ្ញាឆ្នាំ២០១៧។ អំឡុងពេលនៃការបណ្តុះបណ្តាល សិក្ខាកាមបានរៀន និងធ្វើតេស្តសាកល្បងប្រើប្រាស់ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រ និងបានផ្តល់ធាតុចូលបន្ថែមទៀត រួមទាំងការពិភាក្សាពីការបង្កើតក្រុមការងារដែលត្រូវធ្វើបច្ចុប្បន្នភាពឧបករណ៍នេះ។
- ការរៀបចំផែនការបឋម ត្រូវបានចាប់ផ្តើមចងក្រងទិន្នន័យសម្រាប់ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ ដើម្បីបង្កើនសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍នេះ និងរៀបចំផែនការបន្សាំដោយក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធ។
- សំណើដើម្បីបង្កើតក្រុមការងារពិសេសជាមួយក្រសួងអនុវត្តកម្មវិធីSPCR ដើម្បីធ្វើឱ្យឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ កាន់តែត្រូវបានប្រើប្រាស់យ៉ាងសកម្ម។

### **លទ្ធផលទី២៖ ការសិក្សាលទ្ធភាពពីលទ្ធភាពគម្រោងបន្សាំ (ការសិក្សាលម្អិតពីលទ្ធភាពសម្រាប់គម្រោង ដែលត្រូវបានជ្រើសរើសនៃកម្មវិធីសកម្មភាពជាតិ បន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានអនុវត្ត)**

- ទស្សនាទានគម្រោងបន្សាំចំនួន៦ ដើម្បីផ្ញើជូនហិរញ្ញប្បទានអន្តរជាតិសម្រាប់ការរៀបចំផែនការបន្សាំក្នុងវិស័យអាទិភាព ដូចជាវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍក្រុង ត្រូវបានបញ្ចប់រួចរាល់សម្រាប់ការពិនិត្យឡើងវិញជាមួយក្រសួងតាមវិស័យ។
- ការចុះទស្សនកិច្ចវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សាំតាមតំបន់ ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ការវិភាគបច្ចេកទេស សេដ្ឋកិច្ច បរិស្ថាន សង្គមនិងយេនឌ័រ ត្រូវបានអនុវត្តដើម្បីរៀបចំការសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំនីមួយៗ។
- សិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលបឋម នៃការវាយតម្លៃយេនឌ័រ និងសេដ្ឋកិច្ចសង្គមពីការសិក្សាលម្អិតលទ្ធភាពកសាងសំណើគម្រោងបន្សាំ បានរៀបចំនៅរាជធានីភ្នំពេញនាថ្ងៃទី២៩ ខែកញ្ញាឆ្នាំ២០១៧។
- របាយការណ៍ស្តីពីការសិក្សាលម្អិតលទ្ធភាពកសាងសំណើគម្រោងបន្សាំចំនួន៦ កំពុងត្រូវបានរៀបចំ និងគ្រោងបញ្ចប់នៅដើមឆ្នាំ២០១៨ ។




- ប្រភពហិរញ្ញប្បទានបន្សាំអន្តរជាតិ ត្រូវបានស្វែងរក និងពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្ញើសំណើគម្រោង។
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ធនាគារ

អាល្លឺម៉ង់ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាដើម្បីស្វែងយល់ពីចំណាប់អារម្មណ៍របស់ពួកគេក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងបន្សាំដែលបានស្នើឡើង។

- សេចក្តីព្រាងឯកសារ ត្រូវបានរៀបចំសម្រាប់សិក្ខាសាលាពិគ្រោះយោបល់ដែលនឹងត្រូវធ្វើឡើងនៅដើមឆ្នាំ២០១៨ ដើម្បីជ្រើសរើសគម្រោងបន្សាំចំនួនពីរក្នុងចំណោម៦សម្រាប់ផ្ញើជូនមូលនិធិអាកាសធាតុសកល និងដៃគូអភិវឌ្ឍន៍នានាដែលចាប់អារម្មណ៍លើការផ្តល់មូលនិធិ។







## លទ្ធផលទី៤៖ ការគ្រប់គ្រងចំណេះដឹង (ឯកសារចំណេះដឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានផលិត និងផ្សព្វផ្សាយ)

### *ការបន្តធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងព័ត៌មាននិងការទំនាក់ទំនង*

- ការធ្វើបច្ចុប្បន្នភាពមាតិកាគេហទំព័រកម្មវិធីSPCR នៅតែបន្ត និងធ្វើឱ្យកាន់តែងាយស្រួលទាញយកព័ត៌មាន។
- Google Drive ត្រូវបានបង្កើតឡើងដើម្បីរក្សាទុកឯកសារពាក់ព័ន្ធគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនៃកម្មវិធីSPCR គ្រប់កញ្ចប់ទាំងអស់។
- ព័ត៌មានរបស់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសកញ្ចប់ “Package A” “Package B” និង”Package C” និងគម្រោងវិនិយោគនៃកម្មវិធីSPCR ត្រូវបានចែករំលែកជាទៀងទាត់ប្រចាំត្រីមាសតាមរយៈព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិចរបស់កម្មវិធីSPCR។

### *ការរៀបចំ និងការចូលរួមក្នុងព្រឹត្តិការណ៍ចែករំលែកចំណេះដឹង*

- សន្និសីទស្តីពី ”ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ និងការបន្សាំ” ត្រូវបានរៀបចំ ដោយសហការជាមួយគម្រោងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយផ្អែកលើសហគមន៍ និងសហគមន៍កសិករប្រើប្រាស់ទឹក នៅខែតុលា ឆ្នាំ២០១៧។
- របាយការណ៍ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ កំពុងត្រូវបានរៀបចំសេចក្តីព្រាង។
- គណៈប្រតិភូមកពីកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ(PPCR) នៃប្រទេសហ្សាំប៊ី និងនាយកប្រតិបត្តិនៃមូលនិធិវិនិយោគអាកាសធាតុ ព្រមទាំងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀត បានចូលរួមក្នុងសន្និសីទថ្នាក់តំបន់ស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ និងការបន្សាំ និងបានចុះពិនិត្យមើលសកម្មភាពអនុវត្តគម្រោងក្រោមកម្មវិធី SPCR នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។
- វីដេអូឯកសារចំនួន៣ ដែលចងក្រងពីការអនុវត្តសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជាក្នុងវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍក្រុងត្រូវបានផលិត។
- សមាជិកក្រុមការងារបានចូលរួមកិច្ចប្រជុំបច្ចេកទេសលើកទី២ ស្តីពីគម្រោងមូលនិធិអាកាសធាតុបៃតង ដែលដឹកនាំដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នៅរាជធានីភ្នំពេញនាថ្ងៃទី២៨ ខែកក្កដាឆ្នាំ២០១៧។ កិច្ចប្រជុំ បានផ្តល់នូវការយល់ដឹងដ៏សំខាន់ស្តីពីការបង្កើតសំណើគម្រោងសម្រាប់មូលនិធិសកលដែលនឹងត្រូវប្រើដើម្បីបង្កើតឯកសារបណ្តុះបណ្តាលនាពេលអនាគត។
- កម្មវិធីSPCR បានសហការជាមួយកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ បានចូលរួមពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០១៧ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងចែកឯកសារចំណេះដឹងពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។
- មន្ត្រីរដ្ឋាភិបាលដែលដឹកនាំកម្មវិធីSPCR បានចូលរួមសិក្ខាសាលាស្តីពីការតាមដាន និងត្រួតពិនិត្យនៅសហរដ្ឋអាមេរិក ដែលរៀបចំដោយមូលនិធិវិនិយោគអាកាសធាតុ កាលពីថ្ងៃទី ២៦-២៧ ខែមេសា ឆ្នាំ២០១៧។
- មន្ត្រីរដ្ឋាភិបាល បានចុះត្រួតពិនិត្យចំនួន២លើក លើការអនុវត្តគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលកំពុងអនុវត្តដោយ អង្គការសង្គមស៊ីវិលនៃគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសក្រោមកម្មវិធីSPCR។

### *ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំកម្មវិធីសិក្សា*

- សៀវភៅជំនួយស្មារតីស្តីពីការប្រែប្រួលអាកាសធាតុ ជាភាសាខ្មែរសម្រាប់សិស្សនៅអនុវិទ្យាល័យ ដែលរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដោយបានដាក់បញ្ចូលមតិយោបល់ពីនាយកដ្ឋានអប់រំបរិស្ថាននៃក្រសួងបរិស្ថាន បានដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីពិនិត្យ និងអនុម័ត។
- ផ្ទាំងរូបភាពស្តីពីការប្រែប្រួលអាកាសធាតុ ដែលរៀបចំដោយនាយកដ្ឋានអប់រំបរិស្ថាននៃក្រសួងបរិស្ថាន បានចាប់ផ្តើមរៀប

ចំសេចក្តីព្រាង និងស្នើឱ្យមានសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ មុនពេលធ្វើតេស្តសាកល្បងការយល់ដឹងជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សនៅក្នុងរាជធានីភ្នំពេញ និងខេត្តមួយចំនួនលើសេចក្តីព្រាងផ្ទាំងរូបភាព និងសៀវភៅជំនួយស្មារតីស្តីពីការប្រែប្រួលអាកាសធាតុ។

- សៀវភៅមេរៀនសម្រាប់និស្សិត ត្រូវបានចងក្រងជាភាសាខ្មែរចំនួន២មុខវិជ្ជា ដោយសហការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម៖ ការណែនាំជាមូលដ្ឋានអំពីការប្រែប្រួលអាកាសធាតុនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម និងបានផ្ញើជូនធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីអនុម័ត។
- ការគាំទ្រថវិកាលើការអនុវត្តសាកល្បងសួនជីវចម្រុះនៅអនុវិទ្យាល័យដោយក្រសួងបរិស្ថាន និងការផ្តល់អាហារូបករណ៍សម្រាប់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវបានស្នើឡើង។

## វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគផ្លូវលំជនបទ

ថវិកាចំនួន១៦លានដុល្លារសហរដ្ឋអាមេរិក (ហិរញ្ញប្បទានឥណទានចំនួន៧លាន និងហិរញ្ញប្បទានឥតសំណងចំនួន៩លាន) ពីមូលនិធិវិនិយោគអាកាសធាតុសម្រាប់អនុវត្តគម្រោងកែលម្អផ្លូវជនបទ ជំហានទី២ នៃកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុដើម្បីតភ្ជាប់បណ្តាញកោះចំនួន៥នៃដងទន្លេមេគង្គ គឺកោះសូទិន កោះមិត្ត កោះថ្មី កោះសំរោង និងកោះពីរ។



សកម្មភាពសំខាន់ៗ នៃគម្រោងតភ្ជាប់បណ្តាញកោះចំនួន៥នៃដងទន្លេមេគង្គគឺ កែលម្អផ្លូវជនបទក្រាលដីក្រហមប្រវែងសរុប៥០គីឡូម៉ែត្រ ទៅជាផ្លូវជនបទក្រាលបេតុង និងសាងសង់កំពង់ចម្លងចំនួន១១ កន្លែង សម្រាប់តភ្ជាប់រវាងបណ្តាកោះទាំង៥ និងភ្ជាប់ពីកោះទៅដីគោក។

លទ្ធផលដែលសម្រេចបាន គឺសាងសង់ផ្លូវបេតុងប្រវែងសរុប ៣២គីឡូម៉ែត្រ ដាក់លូមូលចំនួន៦កន្លែង និងលូប្រអប់ចំនួន៧កន្លែង ។ ដោយឡែក ការសាងសង់កំពង់ចម្លង នឹងត្រូវចាប់ផ្តើមដំណើរការនៅដើមរដូវប្រាំងឆ្នាំក្រោយនេះ។

ដោយឡែក ថវិកាពីមូលនិធិអភិវឌ្ឍន៍ណ័រឌិក ចំនួន៥,៤លានដុល្លារសហរដ្ឋអាមេរិក ក៏បានចូលរួមចំណែកក្នុងការអភិវឌ្ឍលើកោះទាំង០៥ផងដែរ ដោយផ្តោតលើសកម្មភាពអភិវឌ្ឍន៍សំខាន់ៗដលែមានកុខណៈបញ្ជ្រាបភាពធន់នឹងអាកាសធាតុក្នុងគោលបំណងលើកស្ទួយជីវភាពប្រជាជន រស់នៅលើកោះទាំង០៥ឱ្យមានភាពល្អប្រសើរឡើង។ សកម្មភាពសំខាន់ៗទាំងនោះរួមមានការងារកសិកម្មចម្រុះ ការសាងសង់ប្រព័ន្ធធារាសាស្រ្តស្រោចស្រព ឬអាងស្តុកទឹកសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំង និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខភាពនៅថ្នាក់ភូមិ និងអប់រំអំពីសុខភាព។ល។



## កម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុកញ្ចប់ (Package A) បង្កើតគំនិតសម្រាប់ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

រយៈពេល២សប្តាហ៍ក្នុងខែធ្នូនេះ ក្រុមការងារគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកញ្ចប់ “Package A” កំពុងធ្វើការជាមួយក្រសួងពាក់ព័ន្ធចំនួន៤វិស័យដើម្បីពិនិត្យមើលវឌ្ឍនភាពការកសាងសមត្ថភាព នៃការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការងារ និងដើម្បីកំណត់សកម្មភាពដែលអាចបញ្ជ្រាបការបន្សាំ។ កិច្ចប្រជុំតុមូលត្រូវបានធ្វើឡើង ជាមួយក្រុមការងារបច្ចេកទេសបន្សាំនៃក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងត្រូវជួបប្រជុំក្នុងពេលឆាប់ៗខាងមុខនេះ។ ភារកិច្ចចំនួន៣នៃកិច្ចប្រជុំតុមូលគឺ (១)ពិនិត្យមើលឡើងវិញនូវកម្រងសំណួរស្តីពីការប៉ាន់ប្រមាណតម្រូវការកសាងសមត្ថភាព៧S រយៈពេលពីរឆ្នាំបន្ទាប់ពីវាយតម្លៃលើកដំបូងនៅឆ្នាំ២០១៥។ (២)ពិចារណាវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនិងកំណត់ភាពប្រឈមនានា និង (៣)វិភាគភាពខ្លាំង ភាពខ្សោយ ឱកាស កត្តាគំរាមកំហែងនៃការអនុវត្តគម្រោងវិនិយោគក្រោមកម្មវិធីSPCR ព្រមទាំងកំណត់ភាពខ្វះចន្លោះ និងភាពប្រឈមផងដែរ។




***អភិក្រមការរៀបចំផែនការបន្សាំក្នុងវិស័យ***

ការបញ្ជ្រាប ដូចការកសាងសមត្ថភាព គឺជាដំណើរការស្ទើរតែមិនដែលបញ្ចប់ ហើយជាដំណើរការដែលត្រូវបន្តទៅមុខជាបន្តបន្ទាប់។ ក្រុមការងារកម្មវិធីSPCR បានប្រើប្រាស់ឧបករណ៍មួយ គឺអភិក្រមសម្រាប់រៀបចំផែនការបន្សាំ ដើម្បីជួយកំណត់ចំណុចចាប់ផ្តើម សម្រាប់ការបញ្ជ្រាបគោលនយោបាយនីមួយៗទៅនឹងវដ្តនៃការអនុវត្តគម្រោង។ គោលនយោបាយនិងផែនការសកម្មភាពសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុមានរួចហើយ និងសេចក្តីព្រាងច្បាប់ស្តីពីបរិស្ថាន បានចែងច្បាស់ពីការទទួលខុសត្រូវរបស់ក្រសួងនីមួយៗ ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងរួមបញ្ចូលការវិភាគផលប៉ះពាល់បឋមលើបរិស្ថាន។

កម្រងសំណួរ៧S ជាសំណួរពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធ ភាពដឹកនាំ ធនធានមនុស្ស ការគាំទ្រ និងជំនាញ ដែលវិភាគចេញជាដ្យាក្រាមពិន្ទុដែលអាចវាយតម្លៃបាន។ លទ្ធផលសម្រាប់ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានបង្ហាញដូចខាងក្រោម។




***លទ្ធផលរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រៀបធៀបទៅនឹងវឌ្ឍនភាពរវាងឆ្នាំ២០១៥-២០១៧***

ទាំងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ យល់ថាបានរីកចម្រើនលើយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ និងភាពដឹកនាំ ប៉ុន្តែមិនសូវមានវឌ្ឍនភាពនៅក្នុងប្រព័ន្ធ បុគ្គលិក ជំនាញនិងការគាំទ្រនៅឡើយទេ។ យោបល់ដែលភ្ជាប់នឹងសំណួរ គឺជួយកំណត់មូលហេតុដែលមានវឌ្ឍនភាពទាំងនោះ។




***លទ្ធផលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ប្រៀបធៀបទៅនឹងវឌ្ឍនភាពរវាងឆ្នាំ២០១៥-២០១៧***

ភាពប្រឈមមួយចំនួនដែលក្រសួងនានាបានលើកឡើងក្នុងការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងគម្រោងវិនិយោគនៃកម្មវិធីSPCR រួមមាន៖

- ថវិកាមានកំណត់សម្រាប់បន្សាំនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្រាប់ប្រតិបត្តិការ ព្រមទាំងថែទាំនៅថ្នាក់សហគមន៍ និងការពង្រឹងគណៈកម្មការកសិករប្រើប្រាស់ទឹក
- ការកសាងភាពធន់នឹងអាកាសធាតុជារឿយៗ ត្រូវបង្កើនការចំណាយបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធពី១៥ ទៅ២០%ហើយការចំណាយបន្ថែមនេះ ត្រូវការបកស្រាយពន្យល់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមិនទាន់មានឧបករណ៍វាយតម្លៃនូវការចំណាយ និងអត្ថប្រយោជន៍ពីការចំណាយបន្ថែមលើការបន្សាំនៅឡើយ។
- ការទទួលបានព័ត៌មានសំខាន់ៗសម្រាប់ការរៀបចំរចនាផ្អែកលើហានិភ័យអាកាសធាតុ ដែលជាញឹកញាប់មានការពិបាក ឧ. ការព្យាករជលវិទ្យា និងជលសាស្ត្រ ឬទឹកក្រោមដី។
- ជំនាញរៀបចំរចនាការបន្សាំនឹងការប្រែប្រួលអាកាសធាតុ គឺខ្វះខាត ហើយអ្នកម៉ៅការមិនសូវពេញចិត្តចំពោះលក្ខខណ្ឌនៃការសាងសង់ដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- កង្វះឧបករណ៍វាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំសម្រាប់ប្រភេទជាក់លាក់នៃហេដ្ឋារចនាសម្ព័ន្ធ
- កង្វះបទដ្ឋានបច្ចេកទេស និងសៀវភៅណែនាំការបន្សាំហេដ្ឋារចនាសម្ព័ន្ធ - សម្រាប់បទដ្ឋានបច្ចេកទេសនាពេលបច្ចុប្បន្ននេះ ឬសម្រាប់បទដ្ឋានបច្ចេកទេសដែលអាចបន្សាំផ្នែកខ្លះដែលធ្វើឱ្យប្រសើរឡើងនៅពេលក្រោយ។
- កង្វះជំនាញបទដ្ឋានបច្ចេកទេសការបន្សាំនៃហេដ្ឋារចនាសម្ព័ន្ធ
- កង្វះឧបករណ៍វិភាគអាកាសធាតុ និងជំនាញអភិវឌ្ឍន៍គម្រោងធន់នឹងអាកាសធាតុ

- កង្វះសូចនាករបន្សាំសម្រាប់តាមដាននិងវាយតម្លៃការបន្សាំនៅកម្រិតផ្សេងៗគ្នា

ដោយផ្អែកលើភាពប្រឈម និងដែនកំណត់របស់ក្រសួងនីមួយៗ ខាងក្រោមនេះជាគំនិតសម្រាប់សកម្មភាពបញ្ជ្រាបដែលត្រូវបានបង្កើតឡើងដើម្បីពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធដូចជា៖

***សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ៖***

- ការអភិវឌ្ឍបន្ថែមលើបទដ្ឋានបច្ចេកទេសផ្លូវថ្នល់ធន់នឹងអាកាសធាតុដែលមានសណ្ឋានខុសៗគ្នា។ នេះនឹងត្រូវបានសិក្សាដោយផ្អែកលើបទពិសោធដែលក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ កំពុងអនុវត្តគម្រោងវិនិយោគនៃកម្មវិធីSPCR
- ការរៀបចំសៀវភៅណែនាំបច្ចេកទេស សម្រាប់បទដ្ឋានបច្ចេកទេសផ្លូវថ្នល់ធន់នឹងអាកាសធាតុ រួមជាមួយបទដ្ឋានកំណត់តម្លៃ
- ការបណ្តុះបណ្តាលវិស្វករផ្លូវថ្នល់នៅថ្នាក់ជាតិ និងថ្នាក់ខេត្តពីការប្រើប្រាស់សៀវភៅណែនាំបច្ចេកទេស
- ការបណ្តុះបណ្តាលអ្នកម៉ៅការសាងសង់ផ្លូវថ្នល់ក្នុងការអនុវត្តបទដ្ឋានបច្ចេកទេសផ្លូវថ្នល់ធន់នឹងអាកាសធាតុ
- ការបង្កើតសូចនាករតាមដាននិងវាយតម្លៃសម្រាប់ភាពធន់នឹងអាកាសធាតុនៅថ្នាក់ក្រសួង

***សម្រាប់ក្រសួងធនធានទឹកនិងឧតុនិយម***

- ការបង្កើតបទដ្ឋានបច្ចេកទេស សៀវភៅណែនាំបទដ្ឋានសម្រាប់ប្រព័ន្ធធារាសាស្ត្រស្រោចស្រពដែលធន់នឹងអាកាសធាតុ
- ការណែនាំស្តីពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- ការបង្កើតសូចនាករប្រសិទ្ធភាពនៃភាពធន់នឹងអាកាសធាតុនៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- ការបណ្តុះបណ្តាលវិស្វករទឹកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពីការប្រើប្រាស់សៀវភៅបទដ្ឋានបច្ចេកទេស
- ការណែនាំអំពីការគ្រប់គ្រងទីជម្រាលសម្រាប់ការគ្រប់គ្រងធនធានទឹក

***សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-- ផ្អែកលើការវិភាគការបញ្ជ្រាបដែលធ្វើឡើងដោយក្រុមការងារកសិកម្ម***

- ការបង្កើតនីតិវិធីសម្រាប់ការត្រួតពិនិត្យអាកាសធាតុជាប្រចាំនៃគម្រោងកសិកម្ម
- ការរៀបចំសៀវភៅណែនាំបច្ចេកទេសសម្រាប់ការវាយតម្លៃហានិភ័យអាកាសធាតុក្នុងវិស័យកសិកម្ម
- ការបង្កើតសៀវភៅណែនាំសម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងសំណើគម្រោង
- ការបង្កើតសូចនាករដើម្បីវាយតម្លៃប្រសិទ្ធភាពនៃភាពធន់នឹងអាកាសធាតុក្នុងវិស័យកសិកម្ម
- ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយយល់ដឹងអំពីបច្ចេកទេសបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងចំណោមបុគ្គលិក
- ការលើកកម្ពស់ការយល់ដឹងពីបច្ចេកទេសបន្សាំនឹងអាកាសធាតុក្នុងវិស័យកសិកម្មឯកជន



កិច្ចប្រជុំនៅក្រសួងសាធារណការ និងដឹកជញ្ជូន



កិច្ចប្រជុំនៅក្រសួងអភិវឌ្ឍន៍ជនបទ



កិច្ចប្រជុំធ្វើក្រសួងធនធានទឹក និងឧតុនិយម



កិច្ចប្រជុំនៅក្រសួងបរិស្ថាន ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងផែនការ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# កិច្ចប្រជុំលើកទី៧
# របស់ក្រុមការងារសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងក្រសួងពាក់ព័ន្ធដែលកំពុងអនុវត្តគម្រោងវិនិយោគ កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៧ នៅរាជធានីភ្នំពេញ បានជួបប្រជុំគ្នាលើកទី៧របស់ក្រុមការងារសម្របសម្រួល។ គោលបំណងនៃកិច្ចប្រជុំគឺ៖

- ពិនិត្យមើលវឌ្ឍនភាព និងភាពប្រឈមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍
- ចែករំលែកសមិទ្ធផលថ្មីៗ និងភាពប្រឈមនៃការអនុវត្តគម្រោងវិនិយោគធន់នឹងអាកាសធាតុ
- ពិចារណាលើលទ្ធផលដែលបានរកឃើញតាមរយៈកិច្ចប្រជុំតុមូលស្តីពីការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- កំណត់លក្ខខណ្ឌមគ្គទេសក៍បញ្ជ្រាប បទដ្ឋានបច្ចេកទេស ឧបករណ៍ និងដំណើរការសម្រាប់វិស័យនីមួយៗ
- ពិភាក្សាចំណុចចាប់ផ្តើមដែលមានសក្តានុពលសម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការតាមវិស័យ និងការអនុវត្តក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស និង
- ពិគ្រោះយោបល់លើឱកាសនានាសម្រាប់កិច្ចសហការ ការគាំទ្រ និងមេរៀនបទពិសោធក្នុងចំណោមគម្រោងវិនិយោគភាពធន់នឹងអាកាសធាតុ



កិច្ចប្រជុំនេះ ដឹកនាំដោយឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានក្រុមការងារសម្របសម្រួលកម្មវិធីSPCR ឯកឧត្តម ជួប ប៉ារីស៍ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបណ្ឌិត ភីតធើ ចនម៉ីណែល ប្រធានដឹកនាំក្រុមការងារហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។

អ្នកចូលរួមកិច្ចប្រជុំគឺអញ្ជើញមកពី ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងផែនការ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងធនធានទឹក និងឧតុនិយម។



បន្ថែមពីនេះ កិច្ចប្រជុំ បានពិនិត្យមើលលើវឌ្ឍនភាពផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ របស់ក្រសួងនីមួយៗ និងភាពប្រឈមក្នុងការអនុវត្តគម្រោងវិនិយោគ។ អ្នកចូលរួមក៏បានចែករំលែកផែនការដែលត្រូវអនុវត្តនាពេលខាងមុខ ដោយដាក់ចេញនូវលក្ខខណ្ឌមួយចំនួនដែលវិស័យនីមួយៗ ត្រូវការដើម្បីបង្កើនការរៀបចំផែនការបន្សាំឱ្យកាន់តែមានប្រសិទ្ធភាព។ ឧបករណ៍ដែលមានសក្តានុពល ត្រូវបានពិភាក្សា រួមមានមគ្គទេសក៍បញ្ជ្រាបភាពធន់នឹងអាកាសធាតុតាមវិស័យ ស្តង់ដារ ឧបករណ៍ និងដំណើរការសម្រាប់វិស័យកសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការអភិវឌ្ឍក្រុង។

អ្នកចូលរួមក៏បានផ្លាស់ប្តូរយោបល់លើអត្ថន័យ នៃពាក្យបញ្ជ្រាបផងដែរ។ កិច្ចប្រជុំបានឯកភាពថា ការបញ្ជ្រាប គឺការធ្វើឱ្យការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាផ្នែកមួយនៃការងារប្រចាំថ្ងៃ។ សកម្មភាពសំខាន់នៃការបញ្ជ្រាប រួមមានការបង្កើតឧបករណ៍ មគ្គទេសក៍ និងកម្មវិធីបណ្តុះបណ្តាលដែលធ្វើឱ្យការបន្សាំកាន់តែច្បាស់លាស់ និងងាយស្រួលសម្រាប់អ្នកទទួលខុសត្រូវលើការបង្កើតគោលនយោបាយ ឬអនុវត្តកម្មវិធី និងគម្រោង។





# ការប្រែប្រួលអាកាសធាតុ និងសហគមន៍ជនជាតិដើមភាគតិចព្នង

មិនធ្លាប់មាននរណាម្នាក់នៅក្នុងសហគមន៍ ចងចាំជនជាតិដើមភាគតិចព្នងចេះរបៀបត្បាញឡើយ។ ពួកគេផលិតសម្លៀកបំពាក់ និងក្រណាត់ជាច្រើនដោយខ្លួនពួកគេផ្ទាល់។ ក្រណាត់ដែលមាននិមិត្តសញ្ញាប្លែកៗ និងរចនាបទនានា ត្រូវបានចាត់ទុកថាជាផ្នែកដ៏មានតម្លៃ នៃអត្តសញ្ញាណវប្បធម៌របស់ពួកគេ។ ពិធីសំខាន់ៗជាច្រើន រួមមានការជូនអំណោយគ្នាទៅវិញទៅមក និងពិធីបុណ្យសាសនាផ្សេងៗទៀត គឺក្រណាត់ភួយ និងកន្សែង ដើរតួនាទីយ៉ាងសំខាន់ជាអំណោយក្នុងពិធីទាំងនេះ។ នៅពេលដែលទំនេរពីការប្រកបរបរកសិកម្ម និងការស្វែងរកអនុផលព្រៃឈើ ស្ត្រីតែងតែត្បាញនៅផ្ទះ ចំណែកបុរសវិញ គឺកម្រខ្លាំងណាស់។



ជនជាតិដើមភាគតិចព្នង បានកំពុងរស់នៅពាសពេញខេត្តមណ្ឌលគិរីអស់រយៈពេលរាប់រយឆ្នាំមកហើយ។ ពួកគេ ជាជនជាតិភាគតិចនៅកម្ពុជា ដែលមានភាសា និងវប្បធម៌របស់ខ្លួនជាក់លាក់។ ដូចគ្នានឹងវប្បធម៌ជនជាតិដើមភាគតិចដែរ វត្តមានរបស់ជនជាតិព្នង បានពឹងផ្អែកយ៉ាងខ្លាំងទៅលើទំនាក់ទំនងសហជីវិតជាមួយប្រព័ន្ធអេកូធម្មជាតិ។ ការប្រែប្រួលអាកាសធាតុ ផ្តល់ផលប៉ះពាល់លើជីវភាពរស់នៅរបស់ពួកគេ។ ជនជាតិព្នង ភាគច្រើនជាកសិករលក្ខណៈគ្រួសារ រស់នៅក្នុងសហគមន៍តូចៗជិតព្រៃ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ជនជាតិព្នង បានទទួលរងការធ្លាក់ចុះនៃទិន្នផលកសិកម្ម ដោយសារការអនុវត្តកសិកម្មបែបបូរាណជាមួយនឹងការប្រែប្រួលលំនាំអាកាសធាតុ។

ប្រទេសកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ ដោយមានការផ្តល់ថវិកាគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ដល់គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នៃកម្មវិធីSPCR សមាគមអភិវឌ្ឍន៍ជនជាតិដើមភាគតិចមណ្ឌលគិរី (MIPAD) និងអង្គការផ្លែន អន្តរជាតិប្រចាំនៅកម្ពុជា បានវាយតម្លៃភាពងាយរងគ្រោះក្នុងសហគមន៍ចុងប៉ាង និងឃុំពូរតាំង។ ដោយផ្អែកលើការវាយតម្លៃក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ អាកាសធាតុមានភាពមិនទៀងទាត់ ដូចជា ភាពរាំងស្ងួតយូរអង្វែង ខ្យល់បក់ខ្លាំង និងទឹកជំនន់ បានជះឥទ្ធិពលអវិជ្ជមានដល់ការដាំដុះដំណាំផ្សេងៗ។ ការផ្លាស់ប្តូរខុសធម្មតានៅក្នុងបរិយាកាសធ្វើឱ្យសហគមន៍ ជួបការលំបាកក្នុងការតាមដានវដ្តជីវិតកសិកម្ម។ វាបានធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេ ក្នុងការរស់ពឹងផ្អែកលើកសិកម្មជាលក្ខណៈគ្រួសារ។ ដោយហេតុនេះ បុរសជាច្រើន បានក្លាយជាកម្មករក្នុងទីក្រុងដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់ទ្រទ្រង់គ្រួសារ។

ចំណែកស្ត្រី ក៏ស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ តាមរយៈការងារផ្សេងៗទៀតផងដែរ។ គ្រួសារនីមួយៗ ហាក់មិនឃើញពីតម្លៃ ក្នុងការថែរក្សាប្រពៃណីតម្បាញរបស់ពួកគេនោះឡើយ។ ការផ្លាស់ប្តូររបៀបរបបរស់នៅ បានធ្វើឱ្យវប្បធម៌និងប្រពៃណីរបស់ពួកគេប្រឈមនឹងការបាត់បង់។

ដើម្បីគាំទ្រដល់សហគមន៍ជនជាតិព្នង សមាគម MIPAD បានសម្រេចជ្រើសរើសយុទ្ធសាស្ត្រដែលអាចឱ្យពួកគេអាចបន្តធ្វើកសិកម្មសម្របនឹងការប្រែប្រួលអាកាសធាតុ ខណៈជួយកាត់បន្ថយការពឹងផ្អែកតែលើកសិកម្មមួយមុខ។ ភូមិដែលចូលរួមក្នុងគម្រោង ត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព។ ជាមួយគ្នានេះដែរ MIPAD និងអង្គការផ្លែនអន្តរជាតិកម្ពុជា ឃើញវប្បធម៌តម្បាញមានស្រាប់ដែលជួយកាត់បន្ថយ ការពឹងផ្អែកលើប្រភពចំណូលរបស់ពួកគេពីភាពមិនទៀងទាត់នៃលំនាំអាកាសធាតុ។ MIPAD បានធ្វើការនៅភូមិចុងប៉ាង និងពូរតាំង ដើម្បីជួយសហគមន៍បង្កើតជាក្រុមតម្បាញ។ ក្រុមទាំងនេះ ត្រូវបានផ្តល់ការបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រត្បាញផ្សេងៗបន្ថែមទៀត។ បទអន្តរាគមន៍នេះ មានគោលបំណងដើម្បីអភិរក្សចំណេះដឹង និងប្រពៃណីជនជាតិដើមភាគតិច ខណៈផ្តល់ឱ្យពួកគាត់នូវសមត្ថភាពបន្សាំ នឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែប្រសើរឡើង តាមរយៈការផ្តល់ជម្រើសផ្សេងៗសម្រាប់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចព្នង។



នាង អ្វ ជាសមាជិកម្នាក់ក្នុងក្រុមត្បាញ បាននិយាយថា ក្រុមបានជួយនាងឱ្យមើលឃើញពីភាពជោគជ័យនៃការរកស៊ីតម្បាញ។ នាង អ្វ បានឱ្យដឹងថា ការធ្វើការជាក្រុម ជួយឱ្យត្បាញកាន់តែប្រសើរឡើងនូវគុណភាព ការច្នៃរចនាម៉ូត និងធ្វើឱ្យផលិតផលកាន់តែមានទីផ្សារ។ នាងនិយាយថា នាងអាចរកប្រាក់បានយ៉ាងហោចណាស់ ១០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ សម្រាប់ការលក់ផលិតផលដែលនាងធ្វើនៅពេលទំនេរ។ នាងបង្កើនការត្បាញកាន់តែច្រើននៅរដូវ ដែលមានអ្នកទេសចរមកលេងច្រើន។ ប្រាក់ចំណូលពីការលក់ផលិតផលត្បាញបច្ចុប្បន្នអាចជួយគ្រួសាររបស់នាងទិញអាហារ និងសម្ភារៈកសិកម្ម។ នាងគិតថា ប្រាក់ចំណូលពីការត្បាញនឹងមានប្រយោជន៍ជាពិសេសក្នុងពេលមានគ្រោះរាំងស្ងួត។

# វឌ្ឍនភាពស្តីពីយេនឌ័រ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

គម្រោងហិរញ្ញប្បទាន សហប្រតិបត្តិការបច្ចេកទេស ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍- កញ្ចប់ “Package C” ទទួលបានសមិទ្ធផលសំខាន់ៗមួយចំនួន ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៧។

**លទ្ធផលគួរឱ្យកត់សម្គាល់មួយចំនួន រួមមាន៖**

- ការវាយតម្លៃតម្រូវការសមត្ថភាពស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ត្រូវបានបញ្ចប់ដោយផ្អែកលើឯកសារចំណេះដឹងដែលមានស្រាប់ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងវិនិយោគការប្រែប្រួលអាកាសធាតុ។
- យ៉ាងហោចណាស់មានសមាជិកគណៈកម្មាធិការប្រែប្រួលអាកាសធាតុ និងយេនឌ័រចំនួន៣៨នាក់មកពីក្រសួងកិច្ចការនារី និង២៦នាក់មកពីក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រី១៦នាក់មកពីខេត្តគោលដៅចំនួន៤ (ខេត្តបាត់ដំបង កំពត កំពង់ធំ និងព្រៃវែង) អ្នកតំណាងសង្គមស៊ីវិលចំនួន៥៦នាក់ដែលបានទទួលជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈអង្គការផ្លែន អន្តរជាតិ និងអង្គការផ្សេងៗទៀត ត្រូវបានបណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។
- ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងត្រូវបានរៀបចំឡើងចំនួន២ដង។
- សិក្ខាសាលាពិគ្រោះយោបល់ចំនួន២ ត្រូវបានរៀបចំដើម្បីបញ្ជ្រាបយេនឌ័រដែលជារបៀបវារៈនៃការអភិវឌ្ឍជាប្រចាំ។
- បន្ទាប់ពីមានយន្តការសម្របសម្រួលគណៈកម្មាធិការប្រែប្រួលអាកាសធាតុ និងយេនឌ័រ បានរៀបចំកិច្ចប្រជុំសម្របសម្រួលចំនួន២ដងជាមួយក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធដោយផ្តោតលើយេនឌ័រ និងការប្រែប្រួលអាកាសធាតុ សៀវភៅណែនាំការបញ្ជ្រាបយេនឌ័រ ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌលទ្ធផលយេនឌ័រ ត្រូវក៏បានបង្កើតឡើងដើម្បីតាមដានលទ្ធផលជាក់លាក់។
- ការប្រជុំរួមគ្នាជាមួយមន្ត្រីសម្របសម្រួលបច្ចេកទេសអន្តរនាយកដ្ឋាននៃក្រសួងកិច្ចការនារី បានរៀបចំឡើងដែលដឹកនាំដោយលោកជំទាវបណ្ឌិតអ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

**លទ្ធផលនិងសកម្មភាព គ្រោងទុកសម្រាប់ខែមករាដល់មិថុនា ឆ្នាំ២០១៨**

- បញ្ចប់សេចក្តីព្រាងផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ
- ផ្តល់ការគាំទ្រដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួងនីមួយៗ
- កសាងសមត្ថភាពរបស់គណៈកម្មាធិការប្រែប្រួលអាកាសធាតុ និងមន្ត្រីទទួលបន្ទុកការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួងពាក់ព័ន្ធ ជាមួយផែនការបង្កើនការយល់ដឹង
- ផ្សព្វផ្សាយសៀវភៅណែនាំដល់ក្រសួងពាក់ព័ន្ធពីការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាពទៅក្នុងគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យទាំង៤ (ភាសាអង់គ្លេសនិងខ្មែរ)
- រៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងលើបញ្ហាឆ្លើយតបយេនឌ័រនិងការប្រែប្រួលអាកាសធាតុដោយសហការជាមួយក្រុមការងារស្ត្រីនៅគ្រប់កម្រិត
- តាមដាននិងវាយតម្លៃផលប៉ះពាល់យេនឌ័រនៃគម្រោងវិនិយោគរបស់កម្មវិធី SPCR និងការវាយតម្លៃសមត្ថភាពរបស់អ្នករៀបចំគោលនយោបាយ និងសង្គមស៊ីវិល
- រៀបចំសេចក្តីព្រាងកម្មវិធីសិក្សាអប់រំពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ







## សមិទ្ធផលសំខាន់ៗក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ដែលជាហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសកញ្ចប់ “គ” របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានបង្កើនរបៀបវារៈ ក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍នៅមូលដ្ឋានក្នុងឆ្នាំកន្លងមក ដោយទទួលបានសមិទ្ធផលសំខាន់ៗមួយចំនួន រួមមាន៖

**ការអភិវឌ្ឍសមត្ថភាពស្ថាប័ន៖**

មន្ត្រីគម្រោងបានចុះសិក្សាស្វែងយល់ តាមបណ្តាខេត្តពីស្ថានភាពជាក់ស្តែងនៃការប្រែប្រួលអាកាសធាតុ (ភាពរាំងស្ងួត ទឹកជំនន់ ការហូរច្រោះ ការកើនឡើងកម្ពស់ទឹកសមុទ្រ) ក្នុងខេត្តពោធិ៍សាត់ តាកែវ កោះកុង និងកំពង់ស្ពឺ ព្រមទាំងស្វែងយល់ពីលទ្ធភាពឆ្លើយតប តាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដែលមានអ្នកចូលរួមផ្តល់ព័ត៌មាន សរុបចំនួន២០០នាក់(ស្រី ៣៩នាក់)។

ឯកសារបច្ចេកទេស “ស្តីពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការ ដោយរដ្ឋាភិបាលមូលដ្ឋាននៅកម្ពុជា” (KP1) ត្រូវបានរៀបចំឡើង។ ចំណែកឯកសារណែនាំផ្លូវការដែលត្រូវបានអនុម័តថ្មីៗនេះ ជាឯកសារថ្មីបំផុតនៃគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ដំណើរការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ និងជាឧបករណ៍វាយតម្លៃភាពងាយរងគ្រោះ ដែលសមស្របសម្រាប់ប្រើប្រាស់។

កិច្ចប្រជុំប្រចាំសប្តាហ៍ និងប្រចាំត្រីមាសរវាងក្រុមការងារទីប្រឹក្សាបច្ចេកទេស និងមន្ត្រីគម្រោង បានជួយដល់ការរៀបចំផែនការ និងថវិកាដើម្បីបណ្តុះបណ្តាលមន្ត្រីនៅថ្នាក់ខេត្ត ឃុំ និងស្រុក។



**ការអភិវឌ្ឍសមត្ថភាពបច្ចេកទេស៖**

សិក្ខាសាលាចំនួន៦ ស្តីពី “វគ្គបណ្តុះបណ្តាលតម្រង់ទិស និងពិនិត្យឡើងវិញការប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋាន” ត្រូវបានរៀបចំនៅខេត្តបាត់ដំបង និងព្រៃវែង សម្រាប់មន្ត្រីនៅថ្នាក់ខេត្ត ស្រុក និងឃុំ។ ការបណ្តុះបណ្តាលមានប្រធានបទខុសៗគ្នាដូចជា៖ ការវិភាគការកាត់បន្ថយភាពងាយរងគ្រោះ ការពិនិត្យមើលហានិភ័យអាកាសធាតុ ភាពធន់នឹងអាកាសធាតុ នៅដំណាក់កាលរៀបចំនិងអនុវត្ត ការរៀបចំផែនការនិងថវិកា និងការត្រួតពិនិត្យ តាមដាននិងវាយតម្លៃ។ អ្នកចូលរួមវគ្គសិក្ខាសាលាបណ្តុះបណ្តាលសរុបមានចំនួន ៤៥៨ នាក់ (ស្ត្រី ៦៦នាក់)។ លទ្ធផលនៃការស្ទង់មតិពីវគ្គបណ្តុះបណ្តាល បានបង្ហាញថា៖ សិក្ខាកាម ពេញចិត្តចំពោះវគ្គបណ្តុះបណ្តាលនេះខ្លាំងណាស់ គឺមានប្រយោជន៍ និងពាក់ព័ន្ធការងារផ្ទាល់។ ឯកសារមេរៀនដំបូងត្រូវបាននិងកំពុងចងក្រងជាកូនសៀវភៅតូចៗ។

**គម្រោងបង្ហាញការអនុវត្តផ្ទាល់៖**

គ្រប់វគ្គបណ្តុះបណ្តាលទាំងអស់ សារៈសំខាន់នៃលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌបច្ចេកទេស សម្រាប់គម្រោងវិនិយោគភាពធន់នឹងអាកាសធាតុ ត្រូវបានយកចិត្តទុកដាក់។ ក្រុមការងារ បានរៀបចំបេសកកម្មមួយទៅខេត្តព្រៃវែង ដោយជួបជាមួយស្រុកពាមជរ និងស្រុកព្រះស្តេច ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់បង្ហាញពីគម្រោង ដែលមានសក្តានុពលពីយោបល់នៅថ្នាក់ស្រុកចំនួន១២នាក់ (ជាអ្នកផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ទំនាក់ទំនង)។ ក្នុងនោះដែរ ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ផ្លូវការជាច្រើនជាមួយដៃគូពាក់ព័ន្ធដែលមានសក្តានុពល (អ្នកផ្តល់ព័ត៌មាន និងដៃគូសំខាន់ៗចំនួន៤៥នាក់) សម្រាប់ការរៀបចំគម្រោងសាកល្បងដែលនឹងត្រូវបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០១៧។



**គ្រោងការហិរញ្ញវត្ថុ៖**

ឯកសារបច្ចេកទេស “ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ” ត្រូវបានរៀបចំសេចក្តីព្រាង ដោយបានជជែកពិភាក្សាយ៉ាងជិតស្និទ្ធ ល្អិតល្អន់ ជាមួយស្ថាប័នពាក់ព័ន្ធ និងមនុស្សសំខាន់ៗ។ ឯកសារបច្ចេកទេសនេះ បានរៀបចំយ៉ាងទូលំទូលាយផ្អែកលើឯកសារគម្រូនៃសេវាហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជានិងធ្វើការផ្តល់អនុសាសន៍សម្រាប់ប្រព័ន្ធលំហូរថវិកាក្នុងការគាំទ្រសកម្មភាពធន់នឹងអាកាសធាតុ នៅថ្នាក់មូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង។

**ការលើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប៖**

ផ្ទាំងរូបភាពផ្សព្វផ្សាយស្តីពី “ដំណើរការរៀបចំដើម្បីបង្កើនភាពធន់នឹងអាកាសធាតុនៅថ្នាក់ក្រោមជាតិ” និងខិត្តប័ណ្ណស្តីពី “សមិទ្ធផលរបស់គម្រោងនៃកម្មវិធីSPCR ដែលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងឆ្នាំ២០១៧” ត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយ។

ដើម្បីអានពីការប្រែប្រួលអាកាសធាតុ ទាក់ទងនឹងជនជាតិដើមភាគតិច សូមអានអត្ថបទខាងក្រោមនេះ៖


Leng, V. (2017). Indigenous People Weaving Culture in Cambodia. Angkor youth for peace and development. Retrieved from http://angkorypd.blogspot.hk/2017/10/indigenous-people-weaving-culture-in.html#

Adger, W., Barnett, J., Chapin, F., & Ellemor, H. (2011). This Must Be the Place: Underrepresentation of Identity and Meaning in Climate Change Decision-Making. Global Environmental Politics, 11(2), 1-25. http://dx.doi.org/10.1162/glep_a_00051

Roncoli, C., Crane, T., & Orlove, B. (2016). Fielding Climate Change in Cultural Anthropology. In Anthropology and Climate Change: From Encounters to Actions (pp. 86-92). Routledge


## កម្ពុជាពីប្រទេសមិនសូវស្គាល់បរិស្ថាន បានក្លាយជាអ្នកចែករំលែកបទពិសោធជាមួយប្រទេសហ្សាំប៊ី



ក្នុងរយៈពេលជាង២០ឆ្នាំមកនេះ វិស័យបរិស្ថានកម្ពុជាបានប្រែមុខមាត់ថ្មី។ កម្ពុជាពីប្រទេសដែលមិនយល់ពីវិស័យបរិស្ថាន និងឆ្លងកាត់សង្គ្រាម បានប្រែក្លាយជាប្រទេសផ្តល់បទពិសោធដល់បណ្តាប្រទេសជាមិត្ត ពីវឌ្ឍនភាពស្តីពីវិស័យបរិស្ថាន។ នៅថ្ងៃទី០២ ខែតុលានេះ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងគណៈប្រតិភូនៃប្រទេសហ្សាំប៊ី (Zambia) ដែលមានសមាជិកប្រមាណ ២០នាក់ដឹកនាំដោយលោកស្រីបណ្ឌិត Auxilia Ponga លេខាធិការអចិន្ត្រៃយ៍ផ្នែកត្រួតពិនិត្យ និងវាយតម្លៃ នៃក្រសួងផែនការអភិវឌ្ឍន៍ជាតិ បានពិភាក្សាការងារនិងផ្លាស់ប្តូរបទពិសោធពីវិស័យបរិស្ថាននៃប្រទេសទាំងពីរ។



ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងប្រធានគណៈប្រតិភូប្រទេសហ្សាំប៊ី បានជជែកពិភាក្សាយ៉ាងស៊ីជម្រៅលើបញ្ហានៃការការពារធនធានធម្មជាតិ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការបង្កើតវេទិការវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ការចូលរួមពីវិស័យឯកជន និងបញ្ហាសង្គមមួយចំនួនទៀតពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

ជាទូទៅ អ្វីដែលធ្វើឱ្យបណ្តាប្រទេសជាមិត្តចង់សិក្សាស្វែងយល់ និងទទួលបទពិសោធពីកម្ពុជានោះគឺការបង្រួបបង្រួមជាតិដែលមានរដ្ឋាភិបាលតែមួយ ភាពជាម្ចាស់ការនៃអនុវត្តបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ការអនុវត្តបានលើការងារគ្រប់គ្រងការប្រែប្រួលអាកាសធាតុការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការពង្រីកផ្ទៃដីការពារ និងអភិរក្សដែលមានរហូតដល់ជាង៧,៥លានហិកតា ការផ្ទេរមុខងារឱ្យដាច់ស្រឡះពីគ្នារវាងការអភិវឌ្ឍ និងការអភិរក្ស ការផ្ទេរអំណាចនៃការគ្រប់គ្រងបរិស្ថានទៅថ្នាក់ក្រោមជាតិ និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុ ការដោះស្រាយលើទស្សនៈផ្ទុយគ្នារវាងសង្គមស៊ីវិល និងរដ្ឋាភិបាលស្តីពីវិស័យបរិស្ថានដែលក្រសួងបានរៀបចំវេទិកាថ្នាក់ជាតិដើម្បីរាយការណ៍និងដោះស្រាយកង្វល់លើវិស័យបរិស្ថាន ការកៀងគរវិស័យឯកជន និងយុវជនឱ្យចូលរួមក្នុងវិស័យបរិស្ថាន ដោយការលើកទឹកចិត្តទទួលស្គាល់ និងផ្តល់រង្វាន់ជាដើម។

មិនត្រឹមតែប៉ុណ្ណោះ ឥរិយាបទនិងផ្នត់គំនិតរបស់ប្រជាពលរដ្ឋជាទូទៅលើវិស័យបរិស្ថាន ត្រូវបានផ្លាស់ប្តូរជាវិជ្ជមានគួរឱ្យកត់សម្គាល់ដែលត្រូវបានចូលរួមចំណែកពីកត្តាស្ថេរភាពនយោបាយ ការរីកចម្រើនសេដ្ឋកិច្ចក្នុងរង្វង់៧%ក្នុងរយៈពេល២០ឆ្នាំ និងសេរីភាពសារព័ត៌មានដែលពលរដ្ឋកម្ពុជាទទួលបាន។



## គណៈប្រតិភូជាតិ និងអន្តរជាតិជាង ១០០ នាក់បានចែករំលែកការរៀនសូត្រពីបទពិសោធនិងវិធីសាស្ត្រសម្រាប់ពេលអនាគតដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំសន្និសីទស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៤ ខែតុលានៅខេត្តសៀមរាប។ អ្នកចូលរួមជាង១០០នាក់ ដែលជាភ្ញៀវជាតិ និងអន្តរជាតិ បានចូលរួមក្នុងការផ្លាស់ប្តូរព័ត៌មានវិធីសាស្ត្រ និងផែនការនាពេលអនាគតដើម្បីពង្រឹងភាពធន់នឹងគ្រោះមហន្តរាយនៅថ្នាក់សហគមន៍។ កម្មវិធីនេះ បានសង្កត់ធ្ងន់លើវិធីសាស្ត្រឆ្លើយតបដែលគិតគូពីយេនឌ័រ និងការដាក់បញ្ចូលនូវការកសាងសមត្ថភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន។ សន្និសីទនេះត្រូវបានគាំទ្រដោយកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) នៅកម្ពុជា ដែលគាំទ្រថវិកាដោយមូលនិធិវិនិយោគអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។




នៅក្នុងសុន្ទរកថាស្វាគមន៍ ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាននិងជាប្រធានសម្របសម្រួលកម្មវិធីSPCR បានគូសបញ្ជាក់ពីតម្រូវការសម្រាប់វិធីសាស្ត្រយេនឌ័រដើម្បីធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅថ្នាក់សហគមន៍។ ឯកឧត្តមបានកត់សម្គាល់ថា "ការទទួលខុសត្រូវកាន់តែច្រើនចំពោះកុមារនិងមនុស្សចាស់ជាបន្ទុកលើស្ត្រី ដែលជាញឹកញាប់ប្រឈមនឹងហានិភ័យខ្ពស់អំឡុងពេលមានគ្រោះមហន្តរាយ"។ ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា "យើងត្រូវការធានាថាសមាជិកសហគមន៍ទាំងអស់រួមទាំងស្ត្រីកំពុងទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់អំពីការត្រៀមបង្ការគ្រោះមហន្តរាយ និងត្រូវធ្វើអ្វីខ្លះនៅពេលមានគ្រោះមហន្តរាយ។ ថ្ងៃនេះយើងនឹងចែករំលែកបទពិសោធនៃការបញ្ជ្រាបយេនឌ័រ នៅកម្ពុជាទៅក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ ហើយយើងចាប់អារម្មណ៍ចង់រៀនបន្ថែមទៀតពីបណ្តាប្រទេសដទៃទៀតលើបញ្ហានេះ និងប្រធានបទផ្សេងៗទៀត"។ លោកក៏បានសង្កត់ធ្ងន់ថា "ការចែករំលែកព័ត៌មានដើម្បីបង្កើនសមត្ថភាព ការផ្តល់ព័ត៌មានទាន់ពេលវេលាអំពីភាពរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះទៅកាន់អ្នកពាក់ព័ន្ធទាំងអស់គឺជាតម្រូវការសំខាន់ ដើម្បីកាត់បន្ថយការបាត់បង់សេដ្ឋកិច្ចជាតិ និងគាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាក៏ដូចជាប្រជាជននៅទូទាំងពិភពលោក។

គណៈប្រតិភូរដ្ឋាភិបាលមកពីប្រទេសហ្សាំប៊ី ដែលជាប្រទេសសាកល្បងមួយទៀតនៅក្រោមកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ ក៏បានចូលរួមនៅក្នុងសន្និសីទនេះផងដែរ ដើម្បីផ្លាស់ប្តូរបទពិសោធវិធីសាស្ត្រដែលមានប្រសិទ្ធិភាពនៅក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅសហគមន៍ ។ ការចូលរួមរបស់គណៈប្រតិភូនេះគឺជាផ្នែកមួយដ៏សំខាន់នៃសកម្មភាពផ្លាស់ប្តូរចំណេះដឹងរវាងប្រទេសកម្ពុជានិងប្រទេសហ្សាំប៊ីដែលត្រូវបានបង្កើតឡើង តាមរយៈការគាំទ្រដោយមូលនិធិវិនិយោគអាកាសធាតុ ។ លើសពីនេះទៀត ពួកគាត់ក៏មានឱកាសបង្ហាញពីបញ្ហាសំខាន់ៗ ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយពិនិត្យមើលការអនុវត្តសហគមន៍អភិវឌ្ឍន៍កសិកម្មរោងម៉ាស៊ីនស្រូវ ប្រព័ន្ធប្រឡាយស្រោចស្រពកសិកម្មនិងលូបង្ហូរទឹកនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ដែលត្រូវបានស្តារឡើងវិញដោយមានការគាំទ្រពីកម្មវិធី SPCR នៅកម្ពុជា ។

លោកស្រី Mafalda Duarte ប្រធានគ្រប់គ្រងកម្មវិធី SPCR នៃមូលនិធិវិនិយោគអាកាសធាតុក៏បានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាដកស្រង់បទពិសោធនៅកម្ពុជាផងដែរ ជាមួយគណៈប្រតិភូមកពីប្រទេសហ្សាំប៊ី អំពីភាពធន់នឹងអាកាសធាតុ ។ គាត់បានចែករំលែកព័ត៌មានអំពីរបៀបដែលមូលនិធិវិនិយោគអាកាសធាតុ កំពុងជួយប្រទេសកម្ពុជា និងបណ្តាប្រទេសនានាដើម្បីដោះស្រាយភាពប្រឈមផ្នែកអាកាសធាតុ តាមរយៈការវិនិយោគប្រកបដោយភាពច្នៃប្រឌិត។ សន្និសីទ ក៏បានប្រមូលផ្តុំអ្នកពាក់ព័ន្ធជាច្រើនមកពីបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ធនាគារអភិវឌ្ឍន៍អាស៊ី តំណាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍន៍នានា។

ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀត ប្រឈមនឹងហានិភ័យខ្ពស់ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងគ្រោះធម្មជាតិជាច្រើន ហើយក៏កំពុងជួបប្រទះនូវទឹកជំនន់និងភាពរាំងស្ងួតស្ទើរតែរាល់ឆ្នាំ។ សហគមន៍ជនបទ បានរងផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់និងភាពរាំងស្ងួត និងខ្យល់ព្យុះ។ ក្នុងឆ្នាំខ្លះការជន់លិចកាន់តែខ្លាំងហើយនាំឱ្យមានការបាត់បង់ជីវិតមនុស្ស ការខូចខាតដំណាំនិងសត្វចិញ្ចឹម រួមទាំងផ្ទះសម្បែង និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍។ ភាពរាំងស្ងួត ក៏បានក្លាយទៅជាគ្រោះមហន្តរាយធ្ងន់ធ្ងរនាពេលថ្មីៗនេះដែលបង្កឱ្យខ្វះខាតទឹកសម្រាប់មនុស្សនិងកសិកម្ម។

ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅសហគមន៍គឺជាវិធីសាស្ត្រសមស្របក្នុងការដោះស្រាយបញ្ហាទាំងនេះ ហើយកំពុងទទួលបានប្រជាប្រិយភាព នៅក្នុងប្រទេសកម្ពុជានិងមហាអនុតំបន់ទន្លេមេគង្គ។ សន្និសីទនេះមានបំណងបង្កើតជាវេទិកាមួយដើម្បីចែករំលែកបទពិសោធក្នុងការអនុវត្ត និងគាំទ្រការ

គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅសហគមន៍។ អ្នកចូលរួមធ្វើបទបង្ហាញបានរៀបរាប់ពីការអនុវត្ត និងយុទ្ធសាស្ត្រល្អៗសម្រាប់ពង្រឹងការត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយតាមសហគមន៍ ដែលជាវិធីច្នៃប្រឌិតថ្មីក្នុងការកសាងសមត្ថភាពសហគមន៍មូលដ្ឋាន ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ និងវិធីសាស្ត្រសម្រាប់ការគ្រប់គ្រងហានិភ័យប្រកបដោយនិរន្តភាព។






## សកម្មភាពបន្ទាប់

| | |
|---|---|
| កុម្ភៈ ២០១៨ | សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីការឆ្លើយតបភាពជន់នឹងអាកាសធាតុ ដែលគិតគូរពីយេនឌ័រ និងជនជាតិដើមភាគតិច |
| កុម្ភៈ ២០១៨ | សិក្ខាសាលាជ្រើសរើសគម្រោងពីរ សម្រាប់ការសិក្សាលម្អិត |
| កុម្ភៈ ២០១៨ | កិច្ចប្រជុំដើម្បីរៀបចំសំណើគម្រោង |
| មីនា ២០១៨ | • កិច្ចប្រជុំក្រុមការងារបច្ចេកទេស ឧបករណ៍បង្រួមមាត្រដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ<br>• កិច្ចប្រជុំស្តីពីការរៀបចំក្រុមការងារបច្ចេកទេសមាត្រដ្ឋានភូមិសាស្ត្រថ្នាក់ខេត្ត |
| មីនា ២០១៨ | សម្ភោធដាក់ឱ្យប្រើប្រាស់មគ្គុទេសក៍បន្សាំ និងករណីសិក្សា ជាមួយក្រសួង និងអ្នកអភិវឌ្ឍន៍ |










ព័ត៌មានបន្ថែម៖
ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី
លោក មាស សុផល នាយកដឹកនាំកម្មវិធី
លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគារមរតកតេជោ ឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧
អ៊ីម៉ែល៖ adbspcrta8179@gmail.com
គេហទំព័រ៖ http://www.spcrcambodia.org/kh/